ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សារលិខិតជូនពរ
## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសខួបកំណើតគម្រប់ជន្មាយុ៤៧ឆ្នាំ ឈានចូល៤៨ឆ្នាំ

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ក្នុងឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លា និងប្រកបដោយសេចក្តីសោមនស្សរីករាយនៃខួបកំណើតគម្រប់៤៧ឆ្នាំ ឈានចូល៤៨ឆ្នាំ នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៤ នេះ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងមន្ត្រីការទូតនៅតាមបណ្តាស្ថានតំណាងកម្ពុជានៅបរទេសទាំងអស់ និងក្នុងនាមរូបខ្ញុំបាទផ្ទាល់ យើងខ្ញុំសូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរជូនចំពោះ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កាយពលមាំមួន បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ ដើម្បីដឹកនាំនាវាកម្ពុជា ឆ្ពោះទៅរកអនាគតមួយដ៏រុងរឿងស្របតាមឆន្ទៈ និងបំណងប្រាថ្នារបស់ប្រជាជន។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវមនោសញ្ចេតនាដឹងគុណដ៏ជ្រាលជ្រៅជូនចំពោះ **សម្តេចធិបតី** ដែលបានយកអស់កម្លាំងកាយ ចិត្ត បញ្ញា ស្មារតី ដើម្បីបន្តដឹកនាំថែរក្សាសន្តិភាព ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី ដែលជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍជាតិ។ ក្នុងរយៈពេល១ឆ្នាំជាងមកនេះ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត ស្វាហាប់ ម៉ឺងម៉ាត់ និងទទួលខុសត្រូវខ្ពស់របស់ **សម្តេចធិបតី** រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បាននិងកំពុងដឹកនាំកម្ពុជាឱ្យមានការអភិវឌ្ឍលើគ្រប់វិស័យ មានប្រព័ន្ធគាំពារសង្គមប្រកបដោយបរិយាបន្ន និងមានសេដ្ឋកិច្ចរីកចម្រើនប្រកបដោយចីរភាព និងសមធម៌ ព្រមទាំងបន្តអនុវត្តគោលនយោបាយការបរទេសឯករាជ្យ ដោយផ្អែកលើច្បាប់ កសាងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយប្រទេសទាំងអស់លើសកលលោក និងចូលរួមយ៉ាងសកម្មចំពោះបុព្វហេតុសន្តិភាព ស្ថិរភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់និងពិភពលោក។

យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោក សូមជួយប្រោះព្រំសព្ទសាធុការពរ បវរសួស្តី ជ័យមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការ ជូនចំពោះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី និងលោកជំទាវបណ្ឌិត ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់** សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

សូម សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវការគោរពស្រឡាញ់ដ៏ជ្រាលជ្រៅបំផុតពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ សុក្រ ១ រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤

សុខ ចិន្តាសោភា

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh